# បស្ចឹមប្រទេស និង អញ្ញាតកម្ម[1]ខ្មែរ

បើគេនិយាយ អំពីបស្ចឹមប្រទេស គឺត្រូវផ្តោត អារម្មណ៍ ទៅលើ ភាពទំនើប ព្រោះពាក្យបស្ចឹមប្រទេសវាក្លាយជាគូរ ជាមួយ ពាក្យ ភាពទំនើប។ យើងដឹងថា របបអាណានិគម គេយកពាក្យ ភាពទំនើបនេះឯង មកធ្វើជា ចរិតលក្ខណៈ នៃ របប ជា បេសកកម្ម សំរាប់ឲ បណ្តាប្រជាជន នៃ ប្រទេសអាណានិគម ឲទទួលប្រយោជន៍បានពី ភាពទំនើបនេះ ជាពិសេសក្នុងវិស័យ វិទ្យាសាស្ត្រ សាធារណសុខាភិបាល រដ្ឋបាល និង សិក្សាធិការជាតិ។ តែយើងដឹងដែរថា របប អាណានិគម នាំចូលមកដែរ នូវ អារ្យធម៌ និង វប្បធម៌ បស្ចឹម សំរាប់ សម្រក់ចូល ក្នុង គតិ នៃ ប្រជាជនអាណានិគមដែរ ព្រោះគេមានជំនឿថា ទង្វើនេះ ជា **បុរេលក្ខខ័ណ្ឌ**[2] ចាំបាច់ អោយគតិ ជនជាតិអាណានិគម អាចមានលទ្ធភាព ទទួលបាន នូវ ភាពទំនើប នៃ បស្ចឹមប្រទេស។ ជំនួបរវាង វប្បធម៌ បស្ចឹម ជាមួយ វប្បធម៌ នៃ ជនជាតិអាណានិគម បង្កើត ជាទំនាស់ តែដោយសារ ប្រទេសអ្នកអាណានិគម គេមានកម្លាំងអាវុធ សំរាប់ប្រឈរមុខទប់ទល់នឹង ទំនាស់នេះ គេអាចភ្ជិបវាបាន មិនឲក្លាយ ជា ការបេះបោរប្រដាប់អាវុធ ប្រឆាំងនឹង អាជ្ញាធរអាណានិគម ក្នុងរយៈពេលដ៏យូរបាន។

ទោះបី ប្រទេសចិន ប្រទេសឥណ្ឌា ដែលជាមហាប្រទេស មាន អារ្យធម៌-វប្បធម៌ ខ្ពង់ខ្ពស់ នៅក្នុងពិភពលោក ក៏ពុំអាចជៀសផុត ពីកណ្តាប់ដៃ នៃ អ្នកអាណានិគម នោះបានដែរព្រោះអាណានិគមនិយម ជា លទ្ធិនយោបាយ មានកម្លាំងយោធាជាមធ្យោបាយ អាចមានលទ្ធភាពវាយលុកយក ប្រទេសជំតូច ដែល គ្មាននយោបាយការពារជាតិពិតប្រាកដ និង កម្លាំងយោធាការពារបូរណភាពទឹកដី មកដាក់ក្រោមអំណាចអាណានិគម។

**វិត្ថាកម្ម**[3] អាណានិគម មានយូរយារណាស់មកហើយ នៅក្នុង ប្រវត្តិសាស្ត្រ នៃមនុស្សជាតិ។ ទីណាមានមនុស្ស មានទឹកដី តែងតែមានជានិច្ច នូវការរាតត្បាត ពីសំណាក់ អ្នកខ្លាំង មកលើ អ្នកខ្សោយ ដើម្បីអំណាច ដើម្បី **បសិទ្ធកម្ម**[4] នៃជីវភាពរស់នៅ ដើម្បី សេដ្ឋកិច្ច ។ល។ របស់ខ្លួន។

នៅទីនេះ យើងលើកតែ នយោបាយអាណានិគមបារាំង មកអធិប្បាយ ព្រោះ នយោបាយនេះ វាមានទំនាក់ទំនង ដោយចំពោះ មកលើ ស្រុកខ្មែរ។ នយោបាយអាណានិគមបារាំង ចាប់មានទម្រង់ ជាឆន្ទះនយោបាយ ពិតប្រាកដ នៅពេលដែលបារាំង ដណ្តើមយកបាន ទីក្រុង Alger មកកាន់កាប់ នៅក្នុងឆ្នាំ ១៨៣០។ ឆន្ទះនយោបាយនេះ ប្តូរទស្សនៈ អាណានិគមនិយម

[1] អញ្ញាតកម្ម= វៀរលែង ; Exception។
[2] បុរេលក្ខខ័ណ្ឌ= លក្ខខ័ណ្ឌជាដំបូង ; précondition។
[3] វិត្ថាកម្ម= ការរាតពង្រីក ; expansion។
[4] បសិទ្ធកម្ម= ការធ្វើឲប្រសើរឡើង ; amélioration។

ពី **វ័យនៃរបកឃើញ**[5] មក វ័យ នៃចក្រពត្តិនិយម។ សកកម្មភាព ជាសកម្ម នៃនយោបាយ អាណានិគមបារាំង នៅក្នុងសតវត្សទី១៩ បែងចែកជា បួនយុគៈ

- ទី១. នៅក្នុងពាក់កណ្តាលសតវត្សទី១៩ វិត្ថាកម្ម នៅក្រៅស្រុក ជាឆន្ទៈនយោបាយ ឃើញច្បាស់ ពីសំណាក់អ្នកនយោបាយ ដូចយ៉ាង មាន គណបក្ស អាណានិគម មាន អាសនៈ នៅក្នុងរដ្ឋសភាមានបង្កើត សមាគម ភូមិសាស្ត្រ ជាច្រើន ដើម្បីសិក្សារ រក ដីថ្មី សំរាប់ កសិកម្ម និង រ៉ែ មាននៅក្រៅប្រទេស សំរាប់ឧស្សហកម្ម។ នេះ ជា ហេតុការ ថ្មីពិត តែមិនទាន់ទុកវា ជាអំពើសំខាន់នៅឡើយនោះទេ នៃនយោបាយ អាណានិគម។

- ទី២. ក្រោយពី បដិវត្តបារាំងមក និង វិត្ថាកម្ម នៅប្រទេស អេហ្សីប របស់លោក ឧត្តមសេនីយ Bonaparte ក្នុងឆ្នាំ ១៧៩៨ ធ្វើឡើង ក្នុងសញ្ញា អារ្យធម៌ សេចក្តីជឿនលឿន នៃសាសនាគ្រិស្ត និង ប្រយោជន៏ពាណិជ្ជកម្ម (ឈ្មួញ ទាសករ ស្ករ ។ល។ ពីពេលនោះមក ប្រទេសបារាំង ចាប់តាំងខ្លួនជាប្រទេស អាចនាំមកឲ ប្រទេសខ្សត់ខ្សោយ នូវបញ្ញាថ្មី, អភិវឌ្ឍន៏, វិទ្យាស្សង្ស, បេច្ចកទេសទំនើប។ តែក៏ជាប្រទេសដើរតួជាអ្នករំដោះ ពលរដ្ឋអេហ្សីប អំពីការសង្កត់សង្កិន នៃចក្រភព **អូតូម៉ង់** និង រំដោះប្រជាពលរដ្ឋ នៃប្រទេស អាលហ្សេរី ពីការជិះជាន់ ពីចក្រភពនេះដែរ។
- ទី៣. អាណានិគមនិយមបារាំង នៅក្នុង សតវត្ស ទី១៩ និងទី២០ ជា អាណានិគម «សំណង»[6] ព្រោះយកការកាន់កាប់ទីក្រុង អាល់ស៊េ ក្នុងឆ្នាំ ១៨៣០ មកសងនឹង ក្ស័យទុននយោបាយផ្ទៃក្នុង គឺ បរាជ័យយោធាបារាំងនៅដំបន់ សេដង់ និង បាត់បង់ដំបន់ អាលហ្សាស-ឡរ៉ែន នៅក្នុងឆ្នាំ ១៨៧១។ ដូចមាននៅក្នុង សំដីជាផ្លូវការ របស់ លោក Hansi[7] និយាយទៅកាន់លោក Jules Ferry[8] ជានាយករដ្ឋមន្ត្រី ស្តីអំពី **សញ្ជ័យ**[9] នៃ ឥណ្ឌូចិន ថាៈ *«ខ្ញុំបាត់បង់កូនពីររូប តែលោក បែរជា យក ឈ្នួលពីរនាក់ មកសងខ្ញុំវិញ* »។ ឥណ្ឌូចិន ក៏ ដូច ប្រទេស តុយណេស៊ី ដែរ នៅពេលនោះត្រូវបារាំង ទុកជាដង្ហើម សេដ្ឋកិច្ចថ្មី សំរាប់ ជួយដល់ ការពិបាក ដែលខ្លួនកំពុងជួបប្រទេះក្នុងវិស័យនេះ នៅក្នុងប្រទេស។ ការនេះ មិនដែលឃើញមានសោះ ក្នុងយុគមុនៗ ក្នុងគតិ អាណានិគមបារាំង។
- ទី៤. បន្ទាប់មក នយោបាយ អាណានិគមនិយម បារាំង ប្រើគ្រប់ មធ្យោបាយ (សេដ្ឋកិច្ច, ហិរញ្ញវត្ថុ, យោធា, ធនធានមនុស្ស) ដែលខ្លួនមានសំរាប់ អនុវត្តិ ឲមានប្រសិទ្ធិភាព។ នៅពេលនោះដែរ នៅអឺរ៉ុប មានបដិវត្តិ ឧស្សាហកម្ម ជាវិជ្ជមាន នាំបន្ថែម ជាមធ្យោបាយថ្មី ដល់បារាំង ដើម្បី ប្រព្រឹត្តនយោបាយ អាណានិគម ឲកាន់តែ ងាយស្រួល ដោយប្រើ អានុភាពយោធា និង សេដ្ឋកិច្ច (**អានុភាពរឹង**[10]) បង្ខំឲប្រជាជនអាណានិគមធ្វើការបំរើប្រយោជន៏អាណានិគម ក្នុងនាម នវូបនីយកម្ម។

[5] វ័យនៃរបកឃើញ= âge de la découverte។
[6] អាណានិគម សំណង= Une colonisation de « compensation »។
[7] Jean-Jacques Waltz, alias **Hansi** ou Oncle **Hansi**, né le 23 février 1873 à Colmar et mort le 10 juin 1951 à Colmar, est un artiste illustrateur français.
[8] **Jules Ferry**, né le 5 avril 1832 à Saint-Dié (Vosges) et mort le17 mars 1893 à Paris, est un homme politique français.
[9] សញ្ជ័យ= ច្បាំងដណ្តើមយក ; conquête។
[10] អានុភាពរឹង= La puissance dure។

ស្ថានភាព នៃ បញ្ហាខ្មែរ ក្នុង សតវត្សទី១៩ មុន អាណានិគមបារាំង មានការ ចុះដុនដាបដល់កំរិត ដែលចាំតែថ្ងៃស្លាប់ ព្រោះគ្មានសម្ថភាព ការពារ អធិបតេយ្យភាពខ្លួន នៅចំពោះ មហិច្ចិតា វាតទីកដី ពីសំណាក់ប្រទេសជិនខាង មានយួននិង សៀម។ ទាំងផ្លូវកម្លាំង និង បញ្ហាដែលខ្មែរធ្លាប់មាននៅក្នុងបុរាណកាល បានបាត់សូន្យ ពីគតិខ្មែរ។ ខ្មែរ ជួបប្រទេះនឹង វិបត្តិ ជំនឿទុកចិត្ត លើ ខ្លួនឯង ដែលជាកត្តា នៃការបំផ្លាញថាមពលជាតិ ដែលខ្មែរយើង ហៅថា «**ព្រលឹងជាតិ**»។ សតវត្សទី១៩ ជា សតវត្ស សឲឃើញ **អត្តង្គត**[11] ដែលគំរាបកំហែង ដោយចំពោះ ដល់អត្តភាព ប្រជាជាតិខ្មែរ។ ស្រុកខ្មែរ បែងចែក ជាពីរដំបន់ រស់ក្រោម ឥទ្ធិពលបរទេសៈ ខាងកើតក្រោមយួន ខាងលិច ក្រោមសៀម។ ព្រះចៅ អង្គដួង ជាមហាក្សត្យខ្មែរ (១៨៤៤-១៨៦០) ក្នុង **សហវិជិតរាជ្យ**[12] នៃមហាក្សត្យ សៀម/យួន។ ក្រុងឧដុង្គ ជាជំរុំការពារតែបុព្វសិទ្ធិ ស្ដេច និង រាជវង្ស តែប៉ុណ្ណោះ ដែលពួកគេ នាំគ្នាទុកជា **ពិនាល័យ**[13] សំរាប់សោយសម្បត្តិសុខ។ តែនៅក្រៅបរិវេណវាំងវិញ ប្រជារាស្ត្រខ្មែរ រស់គ្មានទីរំពឹង ឯកោ ជាប្រជាជន ដែលគេបោះបង់ចោល ទៅក្នុង ធុងទុក្ខវេទនា មិនអាចពិពណ៌នាបានៈ ទុគ៌តភាព វាធំធេងហួសពេក នាំឲប្រជាជនខ្មែរ រស់នៅ ស្ទើរស្ទើនឹង ជិវិតសត្វ។ យំព្រោះឃ្លាន ស្លាប់ដូចសត្វ ខ្លាចមហាក្សត្យ ដូចខ្មោច នេះឯង ជា ជិវភាពប្រជារាស្ត្រខ្មែរ នៅក្នុងសតវត្សទី១៩។ សួរថា តើខ្មែរយើងនៅមានបញ្ញា ឯណាទៅដើម្បី គិតពិចារណា អំពី អនាគត របស់ខ្លួន និងប្រជាជាតិខ្មែរ ? ត្រូវដឹងដែរថាខ្មែរ មិនបានដឹងផង ថា ប្រជាជាតិខ្លួន ធ្លាប់ ជា មហានគរ មាន អារ្យធម៌ វប្បធម៌ខ្ពង់ខ្ពស់នៅក្នុងដំបន់អាស៊ី។ ការលុបដោយខ្លួនឯង នូវប្រវត្តិសាស្ត្រជាតិ ពី សតិខ្មែរ នេះ ជា ការបូកចំនួន នៃបរាជ័យខ្មែរ ជាច្រើនសតវត្ស ដែល ផ្ដុំបាន ជា អត្តង្គតជាប់លាប់ សំរាប់ជាតិខ្មែរ។ ជាតិគ្មានរស្មី នាំឲមានកើតជនពាល ជាច្រើន នៅក្នុង ប្រទេស **ពភក**[14] និង រឹកសាយ នូវសិទ្ធរាជអំណាច ផ្ដាច់ការ។ ក្នុងប្រទេសពភក បែបនេះ បង្កើតឲមាន **ព្យតិរេក**[15] រវាង សេចក្ដីសប្បាយខិលខូច របស់ ក្រុមអ្នកដឹកនាំពុករលួយ មហាសេដ្ឋីទុច្ចរិត នឹងការស្រែកឃ្លានរបស់ រាស្ត្រ។ ព្យតិរេក នេះ មានចែងក្នុង ច្បាប់ពាក្យចាស់បុរាណ ជាការដាស់តឿន ឲមាន ការជួយគ្នា ទៅវិញទៅមក រវាង អ្នកមាន នឹង អ្នកខ្សត់ ព្រោះនៅជំនាន់នោះ សង្គមខ្មែរ ជាសង្គមគ្មានសីលធម៌ នោះឡើយ ៖

*អ្នកមានរក្សាខ្សត់   ដូចលំពត់ព័ទ្ធពីក្រៅ*
*អ្នកប្រាជ្ញរក្សាខ្លៅ   ដូចសំពៅនូវសំប៉ាន។*
*អ្នកខ្ពស់រក្សាទាប   ដោយសភាពធម៌បុរាណ*
*អ្នកឆ្អែតរក្សាឃ្លាន  នាអ្នករុងរក្សាផ្ទារ។*

ព្យតិរេក នេះ ជា បញ្ញាតកម្មខ្មែរ ជាការបញ្ជាក់បន្ថែម នូវការបាត់បង់ សីលធម៌ នៅក្នុងសង្គមខ្មែរ និងលុបបាត់ **ពាហុមន្តី**[16]  ចេះស្គាល់ដឹង អំពី ការ «ល្អ-អាក្រក់» ដែលជា ផ្លូវជីវិត។

[11] សឲឃើញអត្តង្គត= Une décadence avérée។
[12] សហវិជិតរាជ្យ= Condominium។
[13] ពិនាល័យ= Paradis des guerriers courageux et des héros។
[14] ពភក= Boueux។
[15] ព្យតិរេក= ភាពផ្ទុយគ្នា ; contraste។
[16] ពាហុមន្តី= Homme avisé។

យើងអាចសន្និដ្ឋានបានថា នៅក្នុងសតវត្សទី១៩ សង្គមខ្មែរ ហូរចាកចេញអស់នូវបញ្ញា ក្លាយជា **អន្ធការសង្គម**[17]។ សង្គមគ្មានបញ្ញា ជា **រំពា**[18]  សំរាប់ ពួកអ្នកដឹកនាំជាតិផ្តាច់ការ នឹងបរទេស ស្រេកឃ្លានទឹកដី។

តែបើយើងឆ្លុះមើលបន្តិច ឃើញ នៅសល់មាន ពុទ្ធសាសនា ដើរតួ ជា សាសនា និង និងជាអ្នកការពារប្រពៃណីជាតិ។ តែ ពុទ្ធសាសនា ជា **ទិដ្ឋិ**[19] ដូច សាសនាដទៃទៀតដែរ តម្រូវឲអ្នកប្រត្តិបត្តិ គោរព នូវគោលការណ៍ ខ្លួន ជាដាច់ខាត ឥតអាចមានលទ្ធភាព បកស្រាយ អត្ថរវត្ថុបាន នោះឡើយ ពុំនោះទេ ត្រូវគេទុកជា អ្នកប្រទូសនឹងសាសនា។ ហេតុនេះឯង បានជា ពុទ្ធសាសនា មានលក្ខណៈ ត្រឹមតែ ជាសីលធម៌ ដ៏ប្រពៃ សំរាប់មនុស្សលោក ស្វែងរក **អតិសុខ**[20] សំរាប់អាត្មា តែមិនមែន ជា មធ្យោបាយ សំរាប់ឲ មនុស្ស ក្លាយជា បញ្ញាជន នោះបានទេ ព្រោះបញ្ញជនជា **តួសង្គម**[21] ពេញលេញ រស់នៅក្នុងស្ថានភាពផ្លាស់ប្តូរ របស់សង្គម ហើយ ចូលប្រឡូកតាមផ្លូវគំនិត ដើម្បី កែលំអ ជីវិតរស់នៅរបស់មនុស្ស ក្នុងសង្គម ក្នុងផ្នែក សីលធម៌ នៃការរស់នៅរបស់មនុស្ស។ ពុទ្ធសាសនា ជាអ្នកបង្ហាញ មធ្យោបាយ ដល់មនុស្ស សំរាប់ប្រត្តិបត្តិដើម្បីរំដោះទុក្ខ ពីក្នុងចិត្តអាត្មា ឯចំណែក បញ្ញា វិញ ជា ហេតុផល សំរាប់ មនុស្ស យកមកពិចារណា ក្នុងឋានៈ ជា **នាដការ នៃការផ្លាស់ប្តូរ**[22] ដើម្បី សេចក្តីចំរើន នៃសង្គម។ រួមសេចក្តីមក យើងអាចទុក ពុទ្ធសាសនា ជា អភិរក្ស រីឯ បញ្ញា ជា អ្នកកំណែទំម្រង់។ អភិរក្ស គឺពិតជាអ្នកការពារប្រពៃណីជាតិ នៅពេលដែលប្រជាជាតិ ធ្លាក់ទៅក្នុងភគ នៃអត្ថង្គត តែការការពារនៅក្នុង គតិ អភិរក្សនិយម ជា ការការពារ អកម្ម តែប៉ុណ្ណោះ។ ការការពារ សកម្ម ត្រូវចាំបាច់មាន បញ្ញាវន្ត ចូលរួមចំណែក ជា មួយ សកម្មភាពសាសនាព្រោះសកម្មភាព របស់ បញ្ញាវន្តជាការជជែកពិភាក្សា រកហេតុផល អំពី កិច្ចការសាធារណៈ។ តែបញ្ញាវន្តក៏អាចក្លាយជា**និកាយ**[23] ការពារ មនោគមវិជ្ជា ដូច បព្វជិត ឬ ភិក្ខុ ការពារ ទិដ្ឋិ នោះដែរ។ ឧទាហរណ៍ ដូចបញ្ញាវន្ត អ្នកកុម្មុយនិស្តនិយម យក លទ្ធិកុម្មុយនិស្ត ជាទិដ្ឋិ នោះឯង។

ជំនួបជាមួយអាណានិគមបារាំង ជាទំព័រ ថ្មី សំរាប់ បញ្ញាខ្មែរ ក្នុងវិស័យ វិទ្យាស្សាស្ត្រ ដែលជានិមិត្តរូប នៃ ភាពសម័យ ចំពោះខ្មែរ។ ការឈរមុខទល់គ្នា រវាង សម័យ និង ប្រពៃណី បង្កើតបានជា បញ្ញាកូនកាត់មួយ នៅស្រុកខ្មែរ។ ក្នុងសម័យ អាណានិគមបារាំង នៅស្រុកខ្មែរ អ្វីជាសម័យ គឺជា ពន្លឺនៃការចេះដឹង ជា វប្បធម៌ សំរាប់ ធ្វើអភិវឌ្ឍន៍ ដើម្បី **អភិក្រម**[24] នៃសង្គម ដោយយក វិទ្យាស្សាស្ត្រ ជា ជំនឿ ប្រៀបប្រដូចនឹង ជំនឿសាសនា។ លទ្ធិ ថ្មីនេះ ទាក់ទាញ ទឹកចិត្ត យុវជនខ្មែរមួយចំនួន ឲ **អភិជ្ឈា**[25] នឹងភាពសម័យ ទុកវិទ្យាស្សាស្ត្រ ជាតម្លៃដាច់ខាត នូវការចេះដឹង លើសអ្វីទាំងអស់ ព្រោះយល់ឃើញថា វឌ្ឍនភាព នៃជាតិ គឺចាំបាច់ ត្រូវយក វិទ្យាស្សាស្ត្រ មកធ្វើជា កម្លាំងយន្ត ក្នុងការធ្វើ អភិវឌ្ឍន៍ជាតិ។ តែយុវជនភាគច្រើន ស្ថិននៅក្នុង សេចក្តីព្រងើយកន្តើយ នៅចំពោះមុខ វិទ្យាស្សាស្ត្រ ព្រោះវាគ្មាននាំមកនូវអ្វី ដែលអាច

---

[17] អន្ធការសង្គម= Société obscurantiste។
[18] រំពា= សត្វដែលគេបរបាញ់ ; Proie។
[19] ទិដ្ឋិ= Dogme។
[20] អតិសុខ= mieux-être។
[21] តួសង្គម= Acteur social។
[22] នាដការនៃការផ្លាស់ប្តូរ= acteur du changement។
[23] និកាយ= sectarisme។
[24] អភិក្រម= ចំរើន, វឌ្ឍនធម៌ ; progrès។
[25] អភិជ្ឈា= ឈ្លក ; convoitise។

ខ្លួនរស់គ្រាន់បើជាង ជីវភាពខ្លួនសព្វថ្ងៃ នោះឡើយ តែក៏មិនទុក អាណាព្យាបាលបារាំងជា **កាលកណ្ណី**[26] សំរាប់ជាតិខ្មែរនោះដែរ។ បារាំងចូលស្រុកនេះ ចំពោះប្រជារាស្ត្រខ្មែរ ដែលមានចំនួនប្រមាណ៩០លាននាក់ វាគ្មានឃើញមាន **វិក្រាយភាព**[27] ជាក់ស្តែង នៃរបបដឹកនាំជាតិ នោះឡើយ ដ្បិទ បារាំងនៅរក្សាទុក របបសក្តិភូមិ ជារបបដឹកនាំជាតិ។ អាណាព្យាបាល បារាំង បើនិយាយខ្លី គឺជាកិច្ចការព្រះមហាក្សត្យ សុខចិត្ត បែងចែកអំណាច ព្រះអង្គជាមួយនឹង អ្នកការពារព្រះអង្គ ប្តូរនឹងសេចក្តីសុខ របស់ព្រះអង្គផ្ទាល់តែប៉ុណ្ណោះ។ ជំនួបខ្មែរជាមួយ បារាំង បែបនេះឯង បង្កើតជា **ការសន្តាបចិត្ត**[28] ដល់ អ្នកស្នេហាជាតិ និង អ្នកស្រឡាញ់ វិទ្យាស្សង្ស ដ្បិទខ្លួន មាន ជំនឿជាក់ច្បាស់ថា **នវភាព**[29] អាចរំលាយ **អន្ធការនិយម**[30] និង អំណាចផ្តាច់ការ ជា ច្រើនពាន់ឆ្នាំ បាន។

យើងអាចទុក គតិ នៃ **ពន្លឺការចេះដឹង**[31] បែបសម័យ ជាមូលដ្ឋាន នូវការបើកអារម្មណ៍ នៃប្រយោជន៍ជាតិ របស់ បញ្ញាវន្តខ្មែរ។ មូលដ្ឋាន នៃពន្លឺការចេះដឹង ដែលមាន វិទ្យាស្សង្ស ជាបទដ្ឋាន ត្រូវបាន ខ្មែរអ្នកចេះដឹង អនុម័ត ទុកជាផ្លូវដើរ ទៅរក វឌ្ឍនភាព នៃសង្គម តែស្របគ្នានោះដែរ មានខ្មែរមួយក្រុមទៀត យល់ឃើញថា សេរីភាព ជាផ្លូវដើរ ទៅរក វឌ្ឍនភាព។ ក្រុមទី១ ទុកវិទ្យាស្សង្ស ជា តម្លៃដាច់ខាន ឬ ជា ទិដ្ឋិ ឯចំណែក ក្រុមទី២ ទុកវិទ្យាស្សង្ស ជា ឧបករណ៏ របស់ សេរីភាព តែប៉ុណ្ណោះ។ ហើយនៅចន្លោះ ក្រុមទាំងពីរនេះ មានក្រុមទី៣ យល់ឃើញថា គ្រិះជាតិ ជាផ្លូវដើរ ទៅរក វឌ្ឍនភាព។ បើនិយាយឲ្យស្រួលយល់ គឺថា ក្រុមទី១ ជាអ្នកឆ្វេងនិយម ទី២ ជាអ្នកប្រជាធិបតេយ្យសេរីនិយម រីឯ ក្រុមទី៣ វិញ ជាអ្នកជាតិនិយម។ បីក្រុមនេះហើយ ជា នាដការ នៃជីវិតនយោបាយខ្មែរ ក្រោយពី ប្រទេសខ្មែរបានទទួលឯករាជ្យ រហូត មកដល់ ថ្ងៃទី ១៧ មេសា ឆ្នាំ ១៩៧៥ ដែលជាថ្ងៃ អវសាន របស់ បញ្ញាវន្តខ្មែរ នោះដែរ ព្រោះ ពន្លឺការចេះដឹង នៃបស្ចឹមប្រទេស ដែលជាមូលដ្ឋាន នៃបញ្ញាខ្មែរ បានទង្គិចយ៉ាងខ្លាំង នៅតណ្ហូចិនជាមួយនឹង គំនិតបដិវត្តន៏ នៃបក្សកុម្មុយនិស្ត នៅអាស៊ី។ ព្រឹត្តិការណ៏សំខាន់ធំពីរ ដែលទុកជាការប្រែប្រួលសំខាន់ គឺ ជ័យជំនះ បក្សកុម្មុយនិស្តចិន លើ របបចិនជាតិនិយមក្នុងឆ្នាំ១៩៤៩ និង កិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុង Genève ក្នុងឆ្នាំ១៩៥៤។ ព្រឹត្តិការណ៏សំខាន់ទាំងពីរនេះ ជាការទទួលស្គាល់ នូវឥទ្ធិពល កម្លាំងកុម្មុយនិស្ត នៅតណ្ហូចិនពីសំណាក់ បស្ចឹមប្រទេស។ ឧទាហរណ៏៖ សង្គ្រាមនៅ វៀតណាម បញ្ជាក់ច្បាស់ថា មិនមែនជាសង្គ្រាម ដើម្បីរំលាយកម្លាំងកុម្មុយនិស្ត នោះឡើយ តែគ្រាន់តែជា ការការពារ វៀតណាមខាងត្បូង ដែលសហរដ្ឋអាមេរិក ទុកជាមិត្ត នឹង កំពែង ការពារ នូវ **ដំណើរ រសាយ**[32] កម្លាំងកុម្មុយនិស្ត នៅ ដំបន់អាស៊ី ដែល សហរដ្ឋអាមេរិក ឲឈ្មោះថា «ទ្រឹស្តី ដូមីណូ»។ ក្នុងកិច្ចព្រមព្រៀង សន្តិភាព នៅទីក្រុង Paris នាឆ្នាំ ១៩៧៣ គឺ គ្រាន់តែជាការបន្ត ទទួលស្គាល់ កម្លាំងកុម្មុយនិស្ត ពីសំណាក់សហរដ្ឋអាមេរិក បន្តពីបារាំង នាឆ្នាំ ១៩៥៤ តែប៉ុណ្ណោះ។ មកដល់កិច្ចព្រមព្រៀងសន្តិភាព ថ្ងៃទី ២៣ តុលាឆ្នាំ ១៩៩១ គឺគ្មានអ្វី ក្រៅពី ការបោះបង់ តណ្ហូចិន ពីសំណាក់ មហាអំណាចលោក

[26] កាលកណ្ណី= ភាពគំរាមកំហែង ; néfaste។
[27] វិក្រាយភាព= ការប្រែផ្លាស់។
[28] ការសន្តាបចិត្ត= Frustration។
[29] នវភាព= ភាពទំនើប ; Moderne។
[30] អន្ធការនិយម= ភាពល្ងង់ខ្លៅ ; obscurantisme។
[31] ពន្លឺការចេះដឹង= Lumières។
[32] ដំណើររសាយ= Prolifération។

សេរី មានសហរដ្ឋអាមេរិក និង បស្ចឹមប្រទេស ប្រគល់ឲ កម្លាំងកុម្មុយនិស្ត យួន/ចិន តែម្ដង។ បើនិយាយឲស្រួលយល់ កិច្ចព្រមព្រៀង ២៣តុលា នេះ ទោះបីមាន វត្តមាន អង្គការសហប្រជាជាតិ ជាអ្នកគ្រប់គ្រង តែតាមការពិត គឺជា ការសម្រុះសម្រួល រវាង ប្រទេស ចិន/យួន កុម្មុយនិស្ត បែកចែកឥទ្ធិពលគ្នា នៅកម្ពុជា សុទ្ធសាធ ក្នុងគោលបំណង គាំពារ ឥទ្ធិពលលទ្ធិកុម្មុយនិស្តនៅឥណ្ឌូចិន ក្រោយពីការរំលំ ប្រព័ន្ធ សូវៀត ឬ កុម្មុយនិស្ត នៅ អឺរ៉ុប។ ជ័យជំនះកម្លាំងកុម្មុយនិស្តនៅឥណ្ឌូចិន ដោយមាន ប្រសិទ្ធិពរ ពីសំណាក់បស្ចិមប្រទេស គឺជា អញ្ញាតកម្មខ្មែរ ដែលមានប្រជាពលរដ្ឋខ្មែរ ជាជនរងគ្រោះ ជានិច្ច ក្នុងអំណាចកុម្មុយនិស្តដូចយ៉ាងក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ក្នុងការកាន់កាប់យោធាវៀតណាម (១៩៧៩-១៩៨៩) និង ក្នុងអាណានិគមវៀតណាម (១៩៩៧ មកដល់សព្វថ្ងៃ) នៅស្រុកខ្មែរ។ ការចេះដឹង នៃបស្ចឹមប្រទេស ហូរចូល មកក្នុង ស្រុកខ្មែរតាម អាណានិគមបារាំង (១៨៦៣-១៩៥៣) ដែលនាំបង្កើតបញ្ញាទំនើបខ្មែរ ត្រូវបាន របបខ្មែរក្រហម រំលាយចោល ក្នុងរយៈពេលដ៏ខ្លីមួយហើយ ត្រូវយួនកុម្មុយនិស្ត បង្ហើយ ទាំងបញ្ញាចាស់ថ្មី របស់ខ្មែរ ឲអស់តែម្ដង។ នេះហើយជា អញ្ញាតកម្មខ្មែរ ដែលបស្ចឹមប្រទេស ទុកជាទង្វើជម្មតា ដូចបារាំង ប្រគល់កម្ពុជាក្រោម ឲទៅប្រទេសវៀតណាម ក្នុងឆ្នាំ ១៩៤៩។ សួរថា តើប្រជាពលរដ្ឋខ្មែរ សុខចិត្ត ទទួលយក អញ្ញាតកម្មនេះ ជា អំពើ «កម្មផល» របស់ខ្មែរ បានដែរឬទេ ? ចម្លើយនឹង សំណួរនេះ គឺមាននៅក្នុង សម្បជញ្ញះ របស់ខ្មែរម្នាក់ៗ តែប៉ុណ្ណោះ។

ឧប សៅ សង្ហា

ថ្ងៃទី ១៣កុម្ភះ ឆ្នាំ ២០១៥